# ព្រះពុទ្ធសាសនាដូចម្តេច?

បោះពុម្ពចែកជាធម្មទាន

ក្នុងឱកាសព្រះរាជពិធីបុណ្យ ព្រះបរមសព

សម្តេចព្រះមហាសូមេធាធិបតីទ្រង់ព្រះនាម

ជួន-ណាត ជោតញ្ញាណោ

ព្រះសង្ឃរាជ គណៈមហានិកាយ

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ព្រះពុទ្ធសាសនាដូចម្តេច?

រៀបរៀងដោយ

ព្រះវីរិយបណ្ឌិតោ ប៉ាង~ខាត់

វត្តឧណ្ណាលោម ភ្នំពេញ

ព.ស. ២៥១៤ គ.ស. ១៩៧០

# សេចក្តីបញ្ជាក់

## សៀវភៅធម៌ដែលមានឈ្មោះថា

## ព្រះពុទ្ធសាសនាដូចម្តេច?

នេះជាស្នាព្រះហស្ថព្រះមហាថេរមួយព្រះអង្គព្រះនាម **ចាំង ខាត់** ជាអ្នកប្រាជ្ញមួយព្រះអង្គមាន ការចេះដឹងយល់ច្បាស់នូវផ្លូវលោកផ្លូវធមិជាសប្បុរសគួរអោយពុទ្ធសាសនិកជនគោរពស្រលាញ់ជឿទុកចិត្ត ចំពោះព្រះទ័យនិងចំណារធមិអាថិផ្សេងៗរបស់លោកដែលសុទ្ធតែជាថេរដីការចំណារត្រឹមត្រូវតាមហេតុផលដូចអត្ថន័យអក្សរសក្នុងសៀវភៅនេះជាអាថិដែលលោករៀបរាប់អំពីរមតិជំនឿរបស់សាសនិកជនដ៏ទៃ នឹងទ្រឹស្តីអត្ថន័យរបស់ព្រះពុទ្ធសាសនាមាន សេចក្តីបញ្ជាក់ច្បាស់លាស់គ្មានស្រពិចស្រពិលគួរអោយខ្មែរកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នាមើលរៀន ជឿតាមអោយបានយល់អំពីៈព្រះពុទ្ធសាសនាបានជាខ្ញុំលះបង់បច្ច័យអោយផែបោះពុម្ពចម្លង ប្រគេនជូនជាធម្មទានក្នុងពេលបុណ្យបញ្ចុះធាតុញោមស្រីនឹងបងប្រុសជាគ្រូរបស់ខ្ញុំដើម្បីជាសារប្រយោជន៍ដល់សាធុជនអ្នកមើល រៀននឹងដើម្បីជាពន្លឺរបស់អ្នកកាន់ព្រះពុទ្ធ សាសនា តទៅអនាគត ។

ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

ចៅអធិការវត្តព្រះពុទ្ធមានបុណ្យ



## ឧបាសិកា ងួន ស៊ាង

**នេះជារូបថតញោមស្រីរបស់អាត្មា**

ញោមស្រីរបស់អាត្មានេះ ញោមប្រុសរបស់អាត្មាបានធ្វើ មរណកាលទៅក្រោយពេលជាអាយុ២០ ឆ្នាំ អាត្មាភាពមានអាយុបាន២ឆ្នាំចាប់តាំងពីពេលនោះមកគាត់កាន់ការកាន់សីលជាប់ជានិច្ចរហូតដល់អាយុ ៦៥ឆ្នាំ ទើបគាត់រក្សាឧបោសថសីល។ លុះពេលអាយុ៨៤ឆ្នាំទើបគាត់ធ្វើមរណកាលដោយជរាពាធនៅផ្ទះលេខ ១៣ ផ្លូវលេខ ២៥២ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការបន ខាងលិចវត្តលង្កា ថ្ងៃ ៣ ១០ ១ ឆ្នាំមមី ទោស័ក ព.ស ២៥៣៤ ត្រូវនឹងថ្ងៃទី ២៧-១១-៩០ វេលាម៉ោង៦.៤៥នាទី ល្ងាច។ បើរាប់ពីឆ្នាំមរណកាលទៅ មកដល់ឆ្នាំនេះ ១០ ឆ្នាំហើយ។

ទីបំផុតនេះធម្មទានជាសៀវភៅឈ្មោះ **ពុទ្ធសាសនាដូចម្តេចគ្នី ?** អាមិសទាន ជាបច្ច័យបូនក្តី កូន ក្មួយ ចៅ ចៅទួត និងអស់លោកសប្បុរសញាតិមិត្តជិតខាង សូមប្រមូលផលានិសង្ស ទាំងពីរមុខនេះ គឺធម្មានិសង្ស និង អាមិសានិសង្ស ឧទ្ទិសចំពោះបុព្វការីជន :

| | |
|---|---|
| ១- លោកតា ងួន យាយ វង | ៦- លោកតា ហេង ធីង និង យាយ ឌិ |
| ២-ញោមប្រុស ហេង គីម ញោមស្រី ងួន ស៊ាង | ៧- លោកតា វ៉ៃ យាយ ប៉ុល |
| ៣-ឪពុកធំ ងួន នៅ ម្តាយធំ សាំង យុត | ៨- ក្មួយ ឈឹម ធុល |
| ៤- ប្អូនថ្លៃ ឈិម ឡុង ប្អូនស្រី ហេង យ៉េន | ៩- ឧបាសក គួច ពាង |
| ៥- បង ឬ លោកគ្រូ ទូច ឡេង | ១០-ឧបាសិកា ហ៊ួន |

ព្រមទាំងជីដូន ជីតា មាតា បិតា ទាំងអស់របស់អស់លោក សប្បុរសដែលបានចូលច្ច័យបោះពុម្ពសៀវភៅធម៌នេះ សូមបាន ទទួលនូវធម្មានិសង្សនេះគ្រប់ៗគ្នា គ្រប់ៗជាតិ និងសូមអោយបាន សំរេចនូវអមតមហានិព្វានក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះ នាមអរិយមេត្តយ្យកុំបីប្រែក្លាយ ទៅជាប្រការដទៃឡើយ ។

ចំពោះ ទស្សនៈ ពិតប្រាកដ អាថ៌កំបាំង សច្ចៈសច្ចធម៌

អ្នកប្រាជ្ញ ( Grands Penseurs ) ទាំងអស់ ព្រមទាំងគ្រប់ពេលវេលា ពីដើមសាសនា កំណត់ហើយ ពោលនៈគឺជាមាន « អាទិទេព ( Dieu ) ជាមហេស្វរ « មហាទេពជាកំពូល » ឬ ប្រជាបតិ « ម្ចាស់សត្វលោក » ។ គំនិតបែបនេះ មាននៅក្នុងគម្ពីរសាសនា មានគម្ពីរវេទ ( ឧបនិសទ ) និងសៀវភៅជាស្នាដៃលោក ប្លាតុង ( Blaton ) អារីស្តូត ( Aristote ) ជាដើម ។ លោកនិងសៀវភៅ សាំងតូម៉ាសដាគីន ( Saint Thomas d' Aquin ) មានសេចក្តីថា « ព្រះជាម្ចាស់ជាព្រះ មានអាទិទេពហើយ » ដែរ ។

ទស្សនវិទូបារាំង កង់ ( Kant ) បានប្រកាន់ស្មារតី « ជំនឿ ដែលជឿស៊ប់ថា មានអាទិទេពនោះ គឺជាគំនិតមានក្នុងសន្តានចិត្ត មនុស្សទូទៅ » ។ លោក ហ្សេហ្គែល ( Hegel ) ថ្លែងថា « គំនិត ដែលជឿថា មានអាទិទេពនេះកើតមានឡើង ក៏ដោយសារតែមានបញ្ហា ដែលជារបស់មនុស្សនេះឡើង » ។ ចំណែក មហាត្មៈគន្ធី លោកក្រុងចិត្ត មានប្រសាសន៍ថា « សច្ចធម៌គឺអាទិទេព » តែ « អាទិទេពពុំមែនជា សច្ចធម៌ទេ » ( Truth is god and not is truth ) ។

អ្នកនិយមសាសនាទាំងអស់ ឬ ពួកបរិស័ទសាសនា ( Religions ) ជាទូទៅ តែងវិញ្ញាណមានជំនឿថាមាន « អាទិទេព » ហើយអាទិទេពនេះ មិនមែនជាអ្វីក្រៅពី « សច្ចធម៌ » នោះទេ ( God is truth ) ពោលគឺអាទិ·

ទេពនេះជា «គោរនៃសច្ចធម៌ = សត្យស្វរូប» ។ សេចក្ដីនេះ បើនិយាយឲ្យងាយយល់ យើងគួរនិយាយថា «អ្នកមេតិកទាំងអស់ បានគន់គិតរកថាអ្វីជាសេចក្ដីពិត = សច្ចធម៌» គេទៅឃើញតាមគំនិតរបស់ខ្លួន ហើយបញ្ញត្តនាមតាមភាសារបស់ខ្លួន បើជាហិណ្ឌូថា ទេវៈ «ទេវតា» បើជាអ្នកបារាំងថា Dieu «អាទិទេព» បើជាចិនថា តៅ «សតាធម៌» តមកក្នុងកាលជាខាងក្រោយ នាមទាំងនេះកើតបានជាបញ្ញត្តសព្ទ ( Concept ) ជាប់គង់សន្តានចិត្តហើយមានជំនឿក្រៅហេតុផល ( Foi, croyance ) នៅកើតឡើង ទើបប្រកាន់យកទិដ្ឋិ (Dogme ) របស់ខ្លួន ។ ព្រះយេស៊ូគ្រិស្ត (Jesus Christ) សម្ដែងទុកថា «សច្ចធម៌ មាននៅក្នុងខ្លួនយើង ហើយធ្វើខ្លួនយើងឲ្យមានសេរីភាព» ។ ឯពាក្យដែលព្រះយេស៊ូទេសនាទុកថា «ចូរស្នេហា ចំពោះព្រះអាទិទេព ឲ្យអស់ពីចិត្ត» នោះ បានសេចក្ដីថា «ចូរស្នេហាព្រះអាទិទេពដោយប្រាជ្ញា ជាធម៌សំខាន់ដែលមាននៅក្នុងខ្លួនមនុស្សលោក» ។

សេចក្ដីពិត ដើមឡើយ គម្ពីរឫគ្វេទបានបញ្ជាក់ថា «ធម្មជាតិ គឺទឹក ដី-ភ្លើង-ខ្យល់ ជាវត្ថុធាតុដើមដែលជនហិណ្ឌូយល់ថា ញ៉ាំងជីវិតខ្លួនឲ្យរស់នៅបាន ទើបគេដាក់នាមថាជា «ទេវៈ = ទេវតា» មិនគឺអ្វីដទៃទេ ។ តមក ក្នុងកាលជាខាងក្រោយ អស់កាលយូរប៉ុន្មានសតវត្សរ៍ ទើបពាក្យថា «ទេវៈ» នេះឯង រីកសាយធំយ៉ាងហើយកើតបានទៅជា «មហាសួរ ឬ ប្រជាបតិ» (Dieu) ទៅតាមសភាវគតិជាធម្មតាមនុស្សលោក ។

សព្វថ្ងៃនេះ ពាក្យថា «ទេវៈ» ដែលគ្រាន់តែជាគុណាធិដ្ឋានឬជាបញ្ញត្តិសព្ទ ( Concept ) នេះ កើតជាឧបក្កិលេសធ្វើឲ្យសៅហ្មង ចាក់ឫសគល់ជាប់ស្អិតក្នុងសន្តានចិត្តមនុស្សសត្វទៅ ក៏បបួលគ្នាឬបន្ទំឲ្យយល់ថាជា «សច្ចធម៌» គោលគឺ "អាមិមេព" ពិតប្រាកដ ហើយបង្កជាទ្រឹស្តីទុកថា «មានទេវតា» ដែលទស្សនវិទូខ្លះទៅប្រើពាក្យថា ភាពមានអត្ថិភាព ( Entité ) នៃទេវតា ។

ឯពាក្យដែលថា " ទេវៈ " ជា "សច្ចធម៌" ឬជា «ឯកសភាពអត្ថិភាពយប» មានសច្ចតែមួយ មិនមានពីរ ( Unique ) នេះទៀត ក៏ជាទ្រឹស្តីរបស់មនុស្សដែលជឿថា «មានទេវតា» ជាពាក្យពោលសេចក្តីឲ្យឃើញថា «មានពិត» ប្រសើរវិសេស ហើយគេទុកជា «សច្ចធម៌» ។ សច្ចធម៌នេះ បើជាមានពិតមែន ក៏ជាសម្មតិសច្ច «សច្ចដោយសន្មត» ពុំមែនជាអរិយសច្ច «សច្ចប្រសើរពិត» នោះទេ ។

ព្រះសម្ពុទ្ធសមណគោតមទ្រង់ពុំមែនជា «អាទិទេព» (God Dieu ) ដូចជាមានទ្រឹស្តីនៃលទ្ធិសាសនា ឬព្រាហ្មណ៍សាសនា បានបញ្ញត្តិទុកមកនោះទេ ។ ព្រះអង្គជា «មនុស្ស» មនុស្សកេសភាវធម៌ពិតឃើញតាមពិត ហើយទ្រង់បានជា «អ្នកយថាភូត» ( Objectif ) ទ្រង់ឃើញតាមពិតថា «ការកើតៈ ជាតិ» នេះជាទុក្ខ ពោលគឺ «បើមានកើតៈ ជាតិ» នេះហើយ ធម៌ទាំងឡាយដែលជាបច្ច័យគឺជរា ព្យាធិ មរណៈ ក៏តែងតែកើតមានឡើងជាធម្មតា ៗ ទ្រង់ឃើញសភាវធម៌ពិតថា «លោកនេះជាទុក្ខ» ដូច្នេះហើយ

ទើបទ្រង់ស្វែងរកផ្លូវប្រតិបត្តិ «បដិបទា» ជាសន្តិបថ «សន្តិភាព» ហៅថា មជ្ឈិមា បដិបទា គឺផ្លូវកណ្តាល ពុំត្រង់ ជាផ្លូវដែលប អាចដោះលោក គឺទុក្ខនៃមនុស្សជាតិនេះបានអស់រលីង មិនគួរមានសង្ស័យឡើយ ។

តើព្រះសម្ពុទ្ធនេះ គឺអង្គលោកណា ?

ប្រមាណជា ៦២៣ ឆ្នាំមុនគ្រិស្តសករាជ កាលនោះ មានសក្យរាជមួយព្រះអង្គកើតឡើងក្នុងនគរដ៏នេប៉ាល់ដែនប្រទេសឥណ្ឌា មាននាមប្រាកដជា គោតម ឬ សិទ្ធត្ថកុមារ ៗ ព្រះជន្មាយុ ១៦ វស្សា ទ្រង់រៀបចំមង្គលាភិសេកជាមួយព្រះនាងពិម្ពាយសោធរា ដែលជាខត្តិយាណីព្រះញាតិជិតដិត ។

អស់កំឡុង ១៣ វស្សា ក្រោយប្រារព្ធអភិសេក ទ្រង់សោយក្តីសុខជាខត្តិយសុខពេលជាតិ ។ ទ្រង់ប្រថាប់នៅក្នុងព្រះបរមរាជវាំងបរិបូណ៌ដោយជាសុខគ្រប់ប្រការ មានប្រាសាទ ៣ខ្នង សំរាប់រដូវកាលទាំង ៣ មួយអាទិ៍ដោយស្រីស្នំក្រមការស្រីស្អាត ច្រៀង រាំ ប្រគំ ដេញ ផ្លុំ ក្បួនគ្រឿងកាន្តព្រះរាជហឫទ័យកតមាននោះហ្នឹងអ៊ូឡើយ សូម្បីតែគ្រឿងទ្រង់ព្រះពស្ត្រភូសា ក៏សុទ្ធសឹងតែការសេយ្យពស្ត្រដែនកាសី ទ្រង់ពុំដែលបានមើលឃើញទុក្ខវេទនា ក្នុងជីវភាពប្រជាជនព្រះអង្គ ដែលរស់នៅក្រៅព្រះបរមរាជវាំងឡើយ ។ លុះកាលវេលាមកដល់ ទើបសង្វេគកើតមានឡើងនៅក្នុងព្រះទ័យព្រះអង្គ ។

ព្រះជន្មាយុ ២៩ ឆ្នាំ ព្រះសិទ្ធត្ថរាជកុមារ ស្តេចចេញប្រពាស ក្រសាលកំសាន្តព្រះទ័យ ទាំងក្រៅព្រះបរមរាជវាំង ទ្រង់បានជ្រាបសេចក្តីពិត ពោលគឺការវិលវល់នូវមរណៈគ្រប់ប្រការទាំងអស់ ដែលបាលីហៅថា "ទុក្ខ = ទុក្ខវេទនា" ពោលគឺសេចក្តីពិតនៃសភាវធម៌ទាំងឡាយ ។ វេលាកាលនោះឯង ព្រះរាជបុត្រគឺរាហុលកុមារប្រសូតថែមទៀត ។ ព្រះទ័យព្រះអង្គទ្រង់រន្ធត់ ដូចត្រូវនឹងបាញ់ទាំងព្រួញពិស ។ ធម៌ទាំងនេះហើយ ជាទេវទូតមកតម្រាមព្រះអង្គ ទ្រង់សម្ងំមួយសន្ទុះ ភ្លាមព្រះអង្គឡើង ទ្រង់ដកដង្ហើមវែង ៗ លាន់ព្រះឱស្ឋខ្សឹប ៗ ថា "អា! កប្បបាប់កន្លងហើយតើ!" ។ ចំណែកបុណ្ណាដើម ដែលទ្រង់ទុកជាអង្គាក់ចង់ព្រះអង្គ ព្រោះថាធម៌ទាំងអស់នេះហើយ សុទ្ធតែជាធម៌នាំឲ្យមាន "ការកើតទៀត = បុនព្ភវ" ។ ដោយទ្រង់យល់ច្បាស់ថា "នេះជាទុក្ខសកលលោក" ទើបទ្រង់មានព្រះទ័យចេញស្វះស្វែងរកឱសថសព្វ-គុណ (Panacea) ដើម្បីព្យាបាលសកលមនុស្សលោក ។

កាលនោះ ព្រះអង្គបោះបង់រាជសម្បត្តិចោលឥតស្រណោះ គាប់យកភេទជាតាបសសន្យាសិន គ្រាប់ង្គាត់ដើរស្វះស្វែងរកសច្ចធម៌ ។ ទ្រង់បានប្រាស្រ័យជាមួយនឹងតាបសច្រើននាក់ ដែលសុទ្ធតែជាអ្នកទទួលស្គាល់ថាជា "បរមគ្រូ" ប៉ុន្តែពុំមានតាបសណា សូម្បីតែម្នាក់ដែលមានភូមិការសិក្សាបរិបូណ៌ ល្មមនឹងថ្វាយវិស្សជ្ជនាដោះកាច់ប្រស្នាឲ្យព្រះអង្គឲ្យពេញព្រះទ័យបានឡើយ ព្រោះតាបសទាំងនោះគ្រាន់តែមាននាមថា

« ទស្សនាវុធ » ប៉ុណ្ណោះ ហើយជាអ្នកមិនមានបញ្ញាចក្ខុ ដូចមនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់ លិចកប់បាត់ទៅក្នុងអវិជ្ជា ដូចសុភាសិតបុរាណខ្មែរថា « ដំរីខ្វាក់ ទ្រមាក់ខ្លួន » ហើយអណ្តែតទៅតាមខ្សែទឹក ពោលគឺវិលវែងវដ្តសង្សារ ។

ក្នុងការស្វែងរកសច្ចធម៌ ទ្រង់សាកល្បងរកគ្រប់វិធី ដែលគេយល់ថាជាផ្លូវនាំទៅកាន់ការរួចចាកទុក្ខ (មោក្ខធម៌) ។ ទ្រង់ប្រព្រឹត្តព្រហ្មចរិយធម៌តាមបែបព្រាហ្មណ៍គឺប្រព្រឹត្តយោគៈ «វិធីទូន្មានចិត្ត» ប្រព្រឹត្តយោគៈហើយ ទ្រង់ឃើញថា ពុំមែនជាផ្លូវត្រង់ទៅកាន់ទីបំផុតទុក្ខ ទ្រង់ប្រព្រឹត្តតបធម៌ «វិធីទូន្មានកាយ» ទៀតដែលយើងគ្រប់គ្នាដឹងថា ទុក្ករកិរិយា «ការធ្វើបានដោយកម្រក្រៃលែង» ។ ព្រះអង្គប្រព្រឹត្តតាមវត្តប្រតិបត្តិសាសនាព្រាហ្មណ៍ទាំងអស់ ដែលគេយល់ថាជាវិធីប្រសើរក្នុងកាលនោះ ទ្រង់ប្រព្រឹត្តលាងបាបមួយបែបហើយមួយបែបទៀត អាំងភ្លើងដុតកំដៅបាបមួយហើយមួយទៀត ទាល់តែព្រះវរកាយស្គាំងស្គមរីងស្ងួត នៅតែស្បែកដណ្តប់ឆ្អឹង មើលទៅឃើញតែគ្រោងឆ្អឹងចង្រឹង ធ្វើម្លឹងហើយ នៅតែមិនបានសម្រេចតាមពុទ្ធបំណងទៀត ។ វិធីព្រហ្មចរិយធម៌បែបនេះហើយពន្យល់ព្រះអង្គថា នេះពុំមែនជាវិធីទេ នេះពុំមែនជាអតិសម័យរបស់ព្រះអង្គទេ ក៏ព្រះអង្គបោះបង់ចោលទាំងអស់ទៅ ហើយតាំងព្រះទ័យស្វែងរកដោយខ្លួនឯងព្រះអង្គវិញ ទ្រង់វៀរផ្លូវចុង ២ ប្រការ គឺការតំនៀយខ្លួនឥតអំពើ ( អត្តកិលមថានុយោគ ) និងការប្រឡូកប្រឡាក់ដោយកាម ( កាមសុខល្លិកានុយោគ )ដាច់ស្រឡះ ។ ការស្វែងរកសច្ចធម៌នៃព្រះអង្គ

នេះ ប្រកបដោយវីរិយភាពខ្លាំងក្លាបំផុត ហួសកម្លាំងមនុស្សធម្មតាដែលមិនអាចធ្វើបាន ហើយត្រូវប្រើវេលាប្រាំមួយវស្សាទៀត ។ ទីបំផុត ទ្រង់ឃើញថា ផ្លូវដែលទ្រង់ប្រតិបត្តិតាមលទ្ធិព្រាហ្មណ៍នេះ ពន្យឺតវេលាផង មិនឲ្យលុះពោធិញ្ញាណ ហើយផ្លូវដែលទ្រង់រកឃើញតាមគំនិតព្រះអង្គនេះ ធ្វើឲ្យព្រះអង្គភ្ញាក់រឭកកើតបញ្ញាញាណបាន ។ ផ្លូវថ្មីដែលទ្រង់រកឃើញ ជាផ្លូវកណ្ដាលហៅថា មជ្ឈិមាបដិបទា ជាផ្លូវប្រើការបាន ត្រង់ទៅរកពោធិញ្ញាណ ហើយបានជាមាគ៌ាត្រង់មួយក្នុងពុទ្ធសាសនា សម្រាប់សកលលោក ។

ព្រឹកថ្ងៃជ័យមង្គលមួយ នាពេញបូណ៌មីខែពិសាខ ទ្រង់ប្រថាប់ក្រោមពោធិមណ្ឌល ឥតមានអនុភាពទេវតាណាមួយមកជួយណែនាំព្រះអង្គទេ មានតែវីរិយនិងបញ្ញាញាណរបស់ព្រះអង្គប៉ុណ្ណោះ ទ្រង់កំចាត់បង់នូវកិលេសាសវៈព្រមទាំងមោហន្ធការដាច់ខាត ហើយទ្រង់លុះសម្មាសម្ពោធិញ្ញាណ «ត្រាស់ដឹងធំ» បានសម្រេចភាពជា «ពុទ្ធ = អ្នកត្រាស់ដឹង» ក្នុងជន្មាយុគម្រប់ ៣៥ វស្សា នៅឧរុវេលប្រទេស (ពុទ្ធគយា) ដែនមគធៈ (រដ្ឋពិហារ) ។ បានត្រាស់ដឹងធំហើយ ទ្រង់ឧទ្ទិសព្រះវរកាយ ព្រះវរជន្មជីត មានតម្លៃឥតអ្វីប្រៀបផ្ទឹមបាន ដើម្បីសកលលោក ដោយពុទ្ធចរិយាជាគម្រូនិងដោយធម្មវិន័យជាដំបូន្មាន ពុំមានមនុស្ស ឬទេវតាណាមួយ ប្រសើរត្រឹមស្មើនឹងព្រះអង្គបានឡើយ ។ ព្រះអង្គទ្រង់បំពេញកិច្ចការពល់ទិវារាត្រីហៅថា **ពុទ្ធកិច្ច** «កិច្ចដែលព្រះពុទ្ធត្រូវធ្វើពល់ទិវារាត្រី» មាន៥ពេលគឺ ៖

១– ពេលព្រឹក ទ្រង់បិណ្ឌបាត;

២– ពេលរសៀល ទ្រង់ប្រទានធម្មទេសនាប្រជាសត្វ;

៣– ពេលពន់ព្រលប់ ទ្រង់ប្រទានឱវាទភិក្ខុសង្ឃ;

៤– ពេលអធ្រាត្រ ទ្រង់វិសជ្ជនាអាថ៌ប្រស្នា ដែលទេវតាមកក្រាបទូលសួរ,

៥– បច្ចូសសម័យ ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ ដែលទ្រង់ត្រូវប្រោស ។

គិតទៅក្នុង២៤ម៉ោង ទ្រង់មិនផ្ទំលក់ដូចមនុស្សធម្មតាទេ ទ្រង់ប្រព្រឹត្តយ៉ាងនេះជានិច្ចកាលអស់រយៈវេលា៤៥វស្សា រហូតដល់និព្វាន គ្រាន់តែសម្រាកព្រះវរកាយមួយស្របក់ ហេតុតម្រង់ព្រះបដិសល្លានដែលព្រះអានន្ទតែងតែក្រាលថ្វាយ ។ ក្នុងលោកនេះ តើមានមនុស្សឬទេវតាណា ធ្វើការដើម្បីសកលលោក មិនចេះឈប់យ៉ាងនេះ ក្នុងមួយជីវិតដូចអង្គព្រះសម្ពុទ្ធដែរឬទេ? ដោយទ្រង់ជាមនុស្សជាតិ ទ្រង់ធ្វើការខ្លាំងពេក ត្រូវតែគាំគ្រាព្រះវរកាយ ត្រូវតែទៅតាមធម៌អនិច្ចំ «ពុំថេរឋាវរ» ហើយបរិនិព្វានក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា ។

សេចក្តីទាំងនេះ បញ្ជាក់គ្រប់គ្រាន់ថា « **ព្រះសម្ពុទ្ធជាមនុស្ស** » ទ្រង់សោយព្រះជាតិជាមនុស្ស មានព្រះជីវិតជាមនុស្ស ដោយទ្រង់ជាមនុស្ស មានព្រះជីវិតផង ទ្រង់ត្រូវតែអស់ព្រះជន្មដូចមនុស្សធម្មតា ។ ប៉ុន្តែព្រះអង្គជាអច្ឆរិយមនុស្ស—មនុស្សអស្ចារ្យ ដែលសកលលោកពុំដែលមាន ។ នេះជាចំណុចធំបំផុត នៅក្នុងសក្តិភាពចំពោះអង្គព្រះសម្ពុទ្ធ ពុំមានឧបមា:

ត្រង់ណាមួយ ដែលគួរឲ្យគិតច្រឡំប្រកាន់ឲ្យយល់ថា « ព្រះអង្គជា អមរៈទេវតា មិនចេះស្លាប់ » នោះឡើយ ។ ដូច្នេះ ពុំគួរចាត់ទុក អង្គព្រះសម្ពុទ្ធជា « អវតារ » ទេ ឬមិនទុកអង្គព្រះសម្ពុទ្ធជាអវតារ (Incarnation) ព្រះវិស្ណុ ដូចអ្នកផងខ្លះតែជឿគេនោះក៏ទេដែរ ឬក៏មិនទុកព្រះអង្គជាជា ត្រាតា « អ្នកជួយលាងបាប » (Saviour) ដែលជួយលាងបាបអ្នកដទៃ ឲ្យរួចចាកកំ ដោយភក្តិមាគ៌ា (Salvation) របស់ព្រះអង្គក៏ពុំមែនទៀត ។ សេចក្តីពិត ព្រះសម្ពុទ្ធជាសាស្តាចារ្យបណ្តុះកម្លាំងចិត្តសាវកព្រះអង្គឲ្យចេះ ទីពឹងខ្លួនឯង ដើម្បីរួចចាកភ័យខ្លួនឯង បញ្ជាក់ឲ្យយល់ពិតថាក្តីបរិសុទ្ធិមិន មិនបរិសុទ្ធិ ស្រេចហើយតែបុគ្គលម្នាក់ៗទេ ។ ក្នុងធម្មបទ ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ទូន្មានថា « អ្នកទាំងឡាយត្រូវធ្វើការឲ្យបានសម្រេចដោយខ្លួនឯង តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវ = តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា » ។ ដូច្នេះ ព្រះសម្ពុទ្ធជាអ្នកចង្អុលប្រាប់ផ្លូវ បង្រៀនឲ្យចេះដើរខ្លួនឯងទុកឲ្យយើងគេប្តេជ្ញាធ្វើខ្លួនឯង ពោលគឺប្រតិបត្តិតាមមាគ៌ាដ៏ត្រង់នោះ ដើម្បីបានក្តីបរិសុទ្ធិខ្លួនឯង ។ និយាយថា «ទីពឹងអ្នកដទៃ ដើម្បីរួចចាកភ័យខ្លួនឯង ជាអវិជ្ជមាន (Negative) ពុំមែនជាវិធីទេ, ទីពឹងខ្លួនឯង ដើម្បីរួចចាកភ័យខ្លួនឯង ទើបជាវិជ្ជមាន (Positive) ទើបជាវិធី ពោលគឺទីពឹងអ្នកដទៃ បានសេចក្តីថា « យើងព្រមទទួលពាញ់វិរិយភាពបុគ្គលដទៃ » ពិតប្រាកដឥតដែកបានឡើយ ។ ពុទ្ធវចនៈដែលបណ្តុះកម្លាំងចិត្តសាវកទាំងឡាយឲ្យចេះទីពឹងខ្លួនឯង ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុក នៅក្នុងមហាបរិនិព្វានសូត្រថា :

«ភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរយកខ្លួនជាកោះពឹងខ្លួនឯង, ចូរយកខ្លួនជាទីពឹង ចូរកុំយករបស់ដទៃមកធ្វើជាទីពឹងខ្លួនឡើយ ។ ភិក្ខវេ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា » ។

ដោយវិសេស ព្រះសម្ពុទ្ធ មិនមានពុទ្ធបំណងនឹងកាន់កាប់កិច្ចការបែបជាឯកាធិបតេយ្យ ( Monopoly ) ឲ្យសម្រេចពុទ្ធភាពដាច់មុខតែមួយព្រះអង្គទេ សេចក្តីពិត ពុទ្ធភាពនេះ ពុំមែនជាបុព្វសិទ្ធិ ( Prerogative ) សម្រាប់បុគ្គលវិសេសណាមួយទេ ទ្រង់បានឡើងឋានៈខ្ពង់ខ្ពស់ប្រសើរយ៉ាងនេះដោយបារមីធម៌ ( State of perfection ) ដែលបុគ្គលណាមួយប្រាថ្នាចង់បាន ក៏អាចសម្រេចបានដូចគ្នាដែរ ពុំមែនជាការបង្គាប់នៃសា-ស្តាចារ្យណាមួយថា បើនឹងបាន លុះត្រាតែបានទទួលទេវត្តការ ហើយទើបសម្រេចបាននោះទេ ។ ពុទ្ធវចនៈដែលមានប្រាកដក្នុងព្រះត្រៃបិដកស្តីមកថា ជនណាម្នាក់ ក៏អាចលុះភាពជាព្រះពុទ្ធបានដូចៗគ្នា ឲ្យតែអ្នកនោះប្រតិបត្តិត្រឹមត្រូវទៅតាមគន្លងបារមីធម៌ ដែលជាមាគ៌ាដើរត្រង់ទៅកាន់ពោធិញ្ញាណ ។ ព្រះសម្ពុទ្ធពុំចេះដាក់ទោសបុគ្គលណាម្នាក់ដោយពុទ្ធដី-កាថា " អ្នកត្រូវបានទោស " ដូច្នេះទេ ផ្ទុយទៅវិញ ទ្រង់តែងតែព្រះមេត្តាប្រោសទេសនាទូន្មានដោយព្រះពុទ្ធដីកាថា;

«ភិក្ខុទាំងឡាយ! ចិត្តជាធម្មជាតបរិសុទ្ធផូរផង់ពីកំណើត តែចិត្តនេះកាលណាបើមានឧបក្កិលេសចូលទៅ ទើបសៅហ្មង = បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ ចិត្តំ អាគន្តុកេហិ ឧបក្កិលេ-សេហិ ឧបក្កិលិដ្ឋំ » ។

តាមពុទ្ធវចនៈនេះ ពិតពេលោកយើងនេះ ពុំមែនជាអាក្រក់ទេ ប៉ុន្តែសត្វទាំងឡាយ តែងតែវង្វេងដោយអំណាចអវិជ្ជា ដែលជាធម៌សឹកសត្រូវធំបំផុតរបស់សត្វទាំងឡាយ ។ ទ្រង់តែងតែមានមេត្តាប្រោសប្រទានទូន្មានដល់សាវកព្រះអង្គកុំឲ្យមានចិត្តញោក ធ្វើសាវកព្រះអង្គឲ្យដកដង្ហើមស្រួលឲ្យរីករាយ ឲ្យអាចហ៊ាន ឲ្យក្លាហាន ឲ្យទុកចិត្តខ្លួនឯង ហើយឲ្យប្រើវិរិយ-ភាពខ្លួនឯងឲ្យមុះមុត ដើម្បីបានឃើញធម៌ដូចព្រះអង្គ ។

ពិសេសទៅទៀត ដោយព្រះអង្គមានភាពជាមនុស្ស ហើយប្រើវិរិយភាពខ្លាំងក្លាឲ្យបានសម្រេចភាពជា " **ពុទ្ធ** " ទ្រង់ប្រកាសប្រាប់លោកទាំងមូលឲ្យយល់ច្បាស់តាមពិតថា „**មនុស្សលោកមានភាពអាចបាន**„ ( Possibilities ) និង **អានុភាពអាចធ្វើឱ្យសម្រេចបាន** ( Creative power) គប់នៅក្នុងខ្លួនមនុស្ស ។ ធម៌ជាអាថ៌កំបាំងទាំងនេះហើយ ទុកជាអាទិទេពមានអំណាចលើមនុស្ស លុះត្រាតែអាទិទេពនេះប្រទាន ទើបមនុស្សលោកអាចសម្រេចប្រយោជន៍ខ្លួនឯងបាន ។ ព្រះសម្ពុទ្ធទ្រង់ចាប់លើកយកធម៌អាថ៌កំបាំងគឺ „**ភាពអាចបាន**„ និង „**អានុភាពអាចធ្វើអ្វីឱ្យបានសម្រេចបាន**„ ទាំងពីរប្រការនេះ ទុកជាធម៌មានតម្លៃប្រសើរបំផុតមកបង្ហាញ មកប្រគេនដល់មនុស្សលោក ព្រមទាំងទេវលោក ឲ្យឃើញច្បាស់ឲ្យយល់ប្រយោជន៍ពិត ។ សេចក្តីពិត មនុស្សលោក ជាតែបណ្ដាក់នៅក្នុងខ្លួនឯងដ៏វិសេស សម្រាប់បក់ប្រាយយកប្រយោជន៍គ្រប់យ៉ាងទាំងលោកនេះនិងបរលោក ។ កសាងខ្លួន ពិតនៅក្នុងខ្លួនមនុស្ស

បិតនៅក្នុងកណ្ដាប់ដៃមនុស្ស ។ ទ្រង់ទេសនាពន្យល់ថា «មនុស្សអាចបានទទួលនិយ្យានិកធម៌ដោយវិរិយភាពខ្លួនឯង មិនបាច់ពឹងពាក់អាទិទេពឬអ្នកណាជាកណ្ដាលណាមួយជួយទេ ។ **អាត្ម័ន**= ព្រលឹងកណ្ដាល (Ego-centric) នៃពិភពលោកនោះ មិនគឺអ្វីផងទេ គឺឧត្ដមគតិដ៏ប្រសើរដែលស្ដីថា «មិនមានខ្លួនឯង= អនត្តា» នេះឯង ។ មិនមានវណ្ណៈ ចាត់ថ្នាក់មនុស្សលោកឲ្យទាបខ្ពស់ពីកំណើតទេ មនុស្សជាតិមានភាពស្មើគ្នា មានកាលគួរត្រូវបានសម្រេចដូចគ្នា នៅក្នុងដំណើរនៃជីវិតមនុស្សគ្រប់គ្នា ។

ព្រះសម្ពុទ្ធជាអ្នកបើកទ្វារឲ្យមនុស្សលោកបានសម្រេចផល ចំរុងចំរើន ថ្មីទៀតតែមានការកើត = ជាតិនេះ ជាកំពែងកពង់ ។ ទ្រង់បើកសេរីភាពពេញបរិបូណ៌ប្រមានដល់សត្វលោក ក្នុងការគិត ការធ្វើ ការនិយាយបំបើកភ្នែកសត្វលោក ឲ្យមើលឃើញអ្វីៗ ឃើញពិតតាមពិតជាយថាភូតទស្សនញ្ញាណ (Objectism) ទ្រង់សម្ដែងធម៌ប្រោសសត្វដែលមានការព្រាត់ប្រាស ឲ្យមានចិត្តរឹងប៉ឹង ឲ្យមានចិត្តក្សេមក្សាន្តដោយពុទ្ធភាសិតគួរឲ្យមានក្ដីកក់ក្ដៅ ។ ទ្រង់ជាគ្រូពេទ្យព្យាបាលរោគចិត្ត ដែលគេរក្សាបានដោយក្រ អ្នកមានជម្ងឺឲ្យចេះបន្សាត់បង់ ឲ្យដកដង្ហើមស្រួលធូរទ្រូង ។ ទ្រង់ជួយអ្នកក្រីក្រដោយព្រះតម្រាស់ឲ្យចេះអប្ប-មាទធម៌ «ធម៌មិនប្រមាទ» ។ ទ្រង់ទូន្មានអ្នកធ្វើអំពើអាក្រក់ ឲ្យចេះធ្វើអំពើល្អ ឲ្យចេះធ្វើខ្លួនឲ្យបរិសុទ្ធ ។ ទ្រង់ទេសនាប្រោសអ្នកប្រួសឲ្យមានក្ដីការហាន អ្នកបំបែកបំបាក់គ្នាឲ្យមានសាមគ្គី, អ្នកល្ងង់ខ្លៅឲ្យចេះដឹង,

អ្នកដែលមានកេចក់ចាំង ឲ្យមានពន្លឺ, អ្នកទាបថោក ឲ្យខ្ពង់ខ្ពស់ អ្នកមិនប្រសើរ ឲ្យបានប្រសើរ ។ អ្នកមាននិងអ្នកក្រ សប្បុរស អសប្បុរសពេញចិត្តព្រះអង្គគ្រប់គ្នា ។ ព្រះអង្គជាសន្តិភាពសន្តិសុខ. ព្រះអង្គជាទសពិធរាជធម៌ ក្សត្រខ្ពង់ខ្ពស់, ក្សត្រទាបថោក, វរជន, មហាសេដ្ឋីចិត្តសប្បុរស, មហាសេដ្ឋីកំណាញ់, អ្នកប្រាជ្ញជាន់ខ្ពស់, អ្នកប្រាជ្ញជាន់ទាប, អ្នកទុរគត គោកយ៉ាក, អ្នកបោសថ្នល់ដែលគេគេបៀតបៀន, ពេជ្ឃាត, ឧតរសោភិទ ទាំងអស់គ្នានេះ សុទ្ធតែត្រូវបានទទួលស្គាល់ពុទ្ធវចនៈ ដែលជាធម៌នាំឲ្យកើតបញ្ញា និងនាំឲ្យកើតព្រហ្មវិហារធម៌ ។

ចរិយាដ៏ប្រសើររបស់ព្រះពុទ្ធ ជាប្រភពដ៏វិសេសសម្រាប់មនុស្សគ្រប់គ្នាអាចយកមកធ្វើជាគម្រូខ្លួន ធ្វើតាមគតិប្រចាំជីវិតខ្លួនបាន ។ មេត្តាគុណ ករុណាគុណ បញ្ញាគុណ របស់ព្រះសម្ពុទ្ធ គួរជាទីជ្រះថ្លា គួរជាទីគោរពបូជា គួរជាទីពេចពិលរមិលមើល នៃពួកជនអ្នកមានសទ្ធាទាំងឡាយ ។ ពុទ្ធវចនៈ ជាប្រភពនាំឲ្យកើតសន្តិភាព ជាធម៌សន្តិវិបច គួរបានទទួលស្វាគមន៍ពីមជ្ឈដ្ឋានទូទៅ ដោយគ្មានការកែប្រែ ហើយជាធម៌ឲ្យផលជានិច្ចនិរន្តរដល់ជនទាំងឡាយ ដែលមានសទ្ធាបានស្តាប់ បានប្រតិបត្តិតាមធម៌ព្រះអង្គ ។ ធម៌ដែលព្រះអង្គបានសំដែងហើយដោយប្រពៃនេះ បានផ្សព្វផ្សាយទូទៅពេញសកលលោក ហើយដក់ជាប់នៅក្នុងសន្តានចិត្ត កើតបានទៅជាធម្មចរិយា ឬជាអរិយធម៌នៃប្រជាជនក្នុងសកលលោក ។ ការជឿនលឿនខាងវប្បធម៌នៃប្រទេសកាន់ពុទ្ធសាសនា

សុទ្ធតែបានមក ដោយអាស្រ័យពុទ្ធវចនៈដ៏ប្រសើរនេះឯង ។ ពុទ្ធសាសនានេះ សូម្បីកើតមានឡើងក្នុងលោក អស់ប្រមាណជា ២៥០៣ ឆ្នាំហើយ តែបុគ្គលិកលក្ខណៈអង្គព្រះសម្ពុទ្ធនិងព្រះធម៌ព្រះអង្គ នៅតែមានឥទ្ធិពលដ៏ខ្លាំងក្លាទៅលើពួកជន ដែលបានទទួលក្រេបផឹករសព្រះធម៌ថ្លៃវិសេសនេះដរាប ។

×

× ×

# ពុទ្ធសាសនា

## ជាលទ្ធិសាសនា = Religion (ពាហិរសាសនា?)

ពុទ្ធសាសនានឹងហៅថា លទ្ធិសាសនាឬពាហិរសាសនា ( Religion) តាមអត្ថន័យនៃពាក្យ ដូចអ្នកផងធ្លាប់យល់មកនោះក៏ទេ ព្រោះពុទ្ធសាស-នាមិនមែនជាប្រព័ន្ធ ( Systéme ) នៃជំនឿឥតហេតុផល ( Croyance ) និងការបូជា ( Culte ) នោះឡើយ ។

ពុទ្ធសាសនាមិនព្រមប្រដៅពុទ្ធសាសនិកជន ឲ្យមានជំនឿឥតហេតុផលទាល់តែសោះ ។ ជំនឿឥតហេតុផលនេះ ពុំមាននៅក្នុងពុទ្ធសាស-នាឡើយ ។ ពុទ្ធសាសនិកជន ប្រើជំនឿដែរ តែជាជំនឿមួយបែបគឺ ជំនឿហេតុផល ជំនឿជាទំនុកចិត្ត ( Confidence ) ហើយមានប្រាជ្ញាប្រកបផង ដែលនៅក្នុងភាសាបាលីលោកហៅថា សទ្ធា « ជំនឿហេតុផលប្រកបដោយបញ្ញា„ ។

ជំនឿឥតហេតុផល គឺជំនឿជឿអាទិទេពថា «អាទិទេពទទួលបាបខ្លួន ឲ្យខ្លួនបរិសុទ្ធ ហើយនាំឲ្យទៅកើតឋានសួគ៌„ ។ ជំនឿបែបនេះ ពុំមែនជា «សទ្ធា„ ដូចក្នុងពុទ្ធសាសនាទេ ។ ជំនឿ «សទ្ធា» ដែលពុទ្ធ-សាសនាប្រដៅឲ្យប្រើ ចំពោះអង្គព្រះសម្ពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានលក្ខណៈជ្រះថ្លាចំពោះគុណធម៌ ហើយមានលក្ខណៈហ៊ានពុះពារដើរទៅតាម គឺមានទំនងដូចអ្នកឈឺ ជឿទុកចិត្តលោកគ្រូពេទ្យថា អាចជួយរក្សាជម្ងឺខ្លួន ឲ្យជាសះស្បើយបាន ហើយហ៊ានកាន់តាមពាក្យទូន្មានលោក

គ្រូពេទ្យ ឬដូចជាសិស្សជឿគ្រូថា គ្រូបាអាចារ្យរបស់ខ្លួន ជាអ្នកបង្រៀនខ្លួនឲ្យចេះចំណេះវិជ្ជាបាន ហើយហ៊ានប្រតិបត្តិតាមពាក្យរបស់គ្រូ ដោយយល់ច្បាស់ថា គ្រូបង្រៀនខ្លួនឲ្យចេះរស់ខ្លួនឯង ឲ្យចេះដើរខ្លួនឯង ។

ពុទ្ធសាសនិកជន យកអង្គព្រះសម្ពុទ្ធជាសរណៈ «ទីពឹង» របស់ខ្លួន ដោយប្រើប្រាជ្ញាញាណពិចារណា តាមហេតុផលសព្វគ្រប់ ឃើញពិតថា «ព្រះអង្គបានឃើញធម៌» ហើយទ្រង់ទេសនាទូន្មានខ្លួន ឲ្យប្រតិបត្តិតាមបដិបទាដែលទ្រង់រកឃើញ ដើម្បីឲ្យបានលុះដល់ផុតទុក្ខ «មោក្ខធម៌» ឬ «និព្វាន» ដូចព្រះអង្គ ។ ពុទ្ធសាសនិកជន មិនព្រមយកព្រះពុទ្ធជាទីពឹង ដោយក្តីសង្ឃឹមថា «ព្រះពុទ្ធទ្រង់ស្រង់ខ្លួន (Salvate) គឺទទួលបាបពីខ្លួនឲ្យខ្លួនបរិសុទ្ធហើយនាំទៅកើតឋានសួគ៌» ដូចគេស្រង់មនុស្សលង់ទឹកដូច្នោះទេ ។ ពុទ្ធសាសនិកជនជឿជាក់ថា «ធម៌អង្គព្រះសម្ពុទ្ធ ពុំមែនជាគ្រឿងស្រង់» (Salvation) នោះទេ ព្រោះព្រះពុទ្ធពុំមែនជា «អ្នកស្រង់» (Saviour) ព្រះពុទ្ធ ពុំដែលធានាអះអាងថា ទទួលលាងបាបសត្វទេ ហើយព្រះពុទ្ធពុំមានអានុភាពទទួលលាងជម្រះបាបអ្នកដទៃបានទៀតផង ។

សេចក្តីពិត មិនមានអ្នកណាដទៃ អាចធ្វើខ្លួនឲ្យបរិសុទ្ធ ក្រៅពីខ្លួនឯងបានឡើយ ។ ការពឹងគេឲ្យជួយបែបនេះ ពុំមែនជាវិធីទេក្នុងលោកនេះ ។ ខ្លួនឯងជួយខ្លួនឯង ទើបជាវិធី ។ ព្រះសម្ពុទ្ធជាសាស្តាចារ្យ ជាអ្នកទូន្មានសត្វ គ្រាន់តែជាអ្នកបង្រៀន ប្រាប់ផ្លូវ សត្វទាំងឡាយត្រូវដើរខ្លួនឯង ទទួលខុសត្រូវដោយខ្លួនឯង ពុទ្ធសាសនិកជន ទោះយោបី

យកព្រះពុទ្ធជាទីពឹង ក៏ពុំមែនបណ្ដោយខ្លួនឲ្យចេះតែជឿតាម ឥតបើគិតនោះទេ ។ ពុទ្ធសាសនិកជន មិនព្រមបោះបង់សេរីភាពខ្លួន ក្នុងការគិតពិចារណារកហេតុផល ហើយចេះតែជឿប្រតិបត្តិអង្គព្រះសម្ពុទ្ធនោះទេ ។ ពុទ្ធសាសនិកជន មានសិទ្ធិសេរីភាពច្បាស់ ក្នុងខ្លួនពេញបរិបូណ៌ ។ ពុទ្ធសាសនិកជន មានសិទ្ធិដើរខ្លួនឯងពេញទី ប្រឹងប្រែងបំពេញបារមីធម៌ ឲ្យចាស់ក្លាទៅដោយខ្លួនឯង ដើម្បីឲ្យខ្លួនឯងលុះភាព « ពុទ្ធ » ពេញទី ដូចអង្គព្រះសម្ពុទ្ធដែរ ។ ព្រះសម្ពុទ្ធជាបរមសាស្ដាចារ្យដ៏លើសក្នុងការប្រទានសេរីភាពដល់សត្វទាំងឡាយ ទ្រង់ទេសនាទូន្មានបង្រៀនសត្វទាំងឡាយឲ្យចេះដើរដោយខ្លួនឯង ពុំមានសាស្ដាចារ្យណាប្រៀបផ្ទឹមឲ្យត្រឹមស្មើនឹងព្រះអង្គបានឡើយ ។ ធម្មវិន័យព្រះអង្គមិនមែនជាអាចារ្យមុដ្ឋិ «កណ្ដាប់នៃអាចារ្យ» (កណ្ដាប់ដៃនៃអាចារ្យ) មិនមែនជាទិដ្ឋិ ( Dogme ) ពុំមែនជាវាទ (Doctrine) មិនមែនជាអន្តវាទ ( Doctrine ésotérique ) មិនមែនជាពហិរវាទ ( Doctrine exotérique ) ទេ = **ទេសិតោ អានន្ទ មយា ធម្មោ អនន្តរំ អពាហិរំ** ។

ក្នុងពុទ្ធសាសនា អ្នកដែលទើបនឹងចូលជាពុទ្ធសាសនិកជន ត្រូវប្រើវិចារណញ្ញាណ ឬត្រូវមានការយល់ត្រឹមត្រូវ ហៅតាមពុទ្ធសាសនាថា សម្មាទិដ្ឋិ «យល់ឃើញត្រឹមត្រូវ» ( vue correcte ) ។ ដើម្បីនឹងបានយល់ពិតតាមគន្លងធម៌ ព្រះសម្ពុទ្ធត្រាស់ទេសនាទុកថា(១)

---

១ កាលាមសូត្រ ។

១– អនុស្សវ កុំប្រកាន់ជឿអ្វីដែលឮតៗគ្នា មិនមានហេតុផល

២– បរម្បរា កុំប្រកាន់ជឿអ្វី ដែលគេធ្វើតៗគ្នា មិនមានដើមចុង

៣– ឥតិកិរ កុំប្រកាន់ជឿអ្វី ដោយអាងថាបានឮគេនិយាយមកដូច្នេះ

៤– បិដកសម្បទា កុំប្រកាន់ជឿអ្វីមើលទៅឃើញសមតាមគម្ពីរខ្លួន

៥– តក្កហេតុ កុំប្រកាន់ជឿអ្វីដោយអាងហេតុប្រស្មានយក (អនុមាន)

៦– នយហេតុ កុំប្រកាន់ជឿអ្វី ដោយអាងការគ្នេរគ្នាន់ឬកាត់តម្រូវ

៧ - អាការបរិវិតក្ក កុំប្រកាន់ជឿអ្វី ដោយអាងការត្រិះរិះមើលតាមអាការ ៗ

៨ - ទិដ្ឋិនិជ្ឈានក្ខន្តិ កុំប្រកាន់ជឿអ្វី ដោយអាងថាខ្លួនពេញចិត្ត

៩– ភព្វរូបតា កុំប្រកាន់ជឿអ្វីថា អ្នកនេះជាអ្នកប្រាជ្ញ គួរជឿតាម

១០– សមណោ នោ គរុ កុំប្រកាន់ជឿថា « សមណៈនេះជាគ្រូយើង » ៗ

ព្រះសម្ពុទ្ធទ្រង់ប្រដៅទៀតថា អ្វីដែលជាកុសល អ្វីដែលប្រសើរ ដែលអ្នកបានឃើញពិតខ្លួនឯង ចូរប្រព្រឹត្តតាមចុះ, អ្វីដែលជាអកុសល អ្វីដែលមិនប្រសើរ ដែលអ្នកបានឃើញពិតខ្លួនឯង ចូរកុំប្រព្រឹត្តឡើយ ៗ ក្នុងលទ្ធិសាសនាដទៃ (Religions) មានពាក្យប្រៀនប្រដៅប្រាកដដូច្នេះឬទេ? ពាក្យប្រៀនប្រដៅនេះ ព្រះសម្ពុទ្ធទ្រង់ទេសនាទុកយូរយារណាស់ហើយ ហើយថិតនៅតាមសំណៅដើមដែល ឃើញហាក់នៅថ្មី ៗ ៗ ចូរពិចារណាមើលចុះ! ពុទ្ធវចនៈនេះ បញ្ជាក់ច្បាស់ថា «ពុទ្ធសាសនា

មិនព្រមប្រើដំនៀងតហេតុផល" នេះទេ ។ បុគ្គលម្នាក់ ៗ មានសិទ្ធិប្រើសេរីភាពរបស់ខ្លួនក្នុងការគិត ការនិយាយ ការធ្វើ ។ គួរកត់ចំណាំទុកចុះថា "ពុទ្ធសាសនាជាសាសនាប្រគល់សេរីភាព" ។ ព្រះពុទ្ធជាអ្នកប្រទានសេរីភាព ពុំមែនជា អាចារ្យមុដ្ឋិ "កណ្ដាប់ដៃនៃអាចារ្យ" ទេ ។

សេចក្ដីខាងលើនេះ មានប្រស្នាចោទសួរថា "ចុះហេតុម្ដេចបានជាពុទ្ធសាសនិកជនគោរពព្រះពុទ្ធបដិមា ?

ពុទ្ធសាសនិកជន គោរពនមស្ការព្រះពុទ្ធបដិមា ពុំមែនសុំក្ដីអនុគ្រោះ ( Faveur ) ពីអាទិទេព ទេ គឺគោរពអ្វីដែលជាតំណាងព្រះសម្ពុទ្ធ ។ ក្នុងពុទ្ធសាសនា ពុំមានសូត្រស្គុត ( Prière ) បន់ស្រន់អាទិទេពទេ ។ ការបូជាគ្រឿងសក្ការៈដូចជា ទៀន ធូប ចំពោះព្រះពុទ្ធបដិមា ជាការបូជាគុណ មេត្តា ករុណា បញ្ញារបស់បុគ្គលប្រសើរដែលបានធ្វើប្រយោជន៍ដើម្បីសកលលោក ធ្វើហាក់ដូចកាលទ្រង់គង់ធរមាននៅឡើយ ហើយយកអង្គព្រះសម្ពុទ្ធជាគម្រូ ជាគតិប្រចាំចិត្ត ប្រតិបត្តិតាមធម្មវិន័យព្រះអង្គ តាមចរិយាព្រះអង្គ ដើម្បីធ្វើខ្លួនឲ្យបានឃើញធម៌ដូចព្រះអង្គ ។

ដោយគោរពកិច្ច ដោយកតញ្ញូតាធម៌ ពុទ្ធសាសនិកជន ត្រូវតែបំពេញកិច្ចទាំងនោះ ដើម្បីបូជាគុណ ។ ព្រះសម្ពុទ្ធមិនមានពុទ្ធបំណងធំចំពោះគ្រឿងសក្ការៈបូជានេះទេ ពុទ្ធបំណងដែលសំខាន់បំផុតនោះ គឺការប្រតិបត្តិតាមធម៌វិន័យ ឲ្យបានត្រឹមត្រូវតាមគន្លងធម៌ ដែលជាវិធីនាំសត្វលោកឲ្យរួចចាកទុក្ខគ្រប់ប្រការ ។ ក្នុងមហាបរិនិព្វានសូត្រទ្រង់ត្រាស់ថា:

«ភិក្ខុទាំងឡាយ! បូជាមាន ២ ប្រការ គឺ អាមិសបូជា និងបដិបត្តិបូជា ។

១– អាមិសបូជា បូជាគ្រឿងសក្ការៈ ទៀន ធូប ផ្កា ការបូជាទាំងនេះ មិនមែនជាការសំខាន់អ្វីពេកទេ តែពុទ្ធសាសនិកជនពេញចិត្តធ្វើ ។

២ – បដិបត្តិបូជា បូជាគឺការប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យព្រះអង្គ ។

បូជាពីរប្រការនេះ បដិបត្តិបូជាគឺការប្រតិបត្តិត្រឹមត្រូវតាមធម្មវិន័យ ជាការបូជាប្រសើរលើស ។ ទ្រង់ត្រាស់ថា ៖ អ្នកណាបូជាព្រះអង្គដោយបដិបត្តិបូជា គឺប្រតិបត្តិត្រឹមត្រូវតាមធម៌ អ្នកនោះឈ្មោះថា គោរព គប់អាន - បូជាតថាគត - ដោយការបូជាដ៏ប្រសើរលើស ។ ក្នុងទីដទៃទៀត ទ្រង់ត្រាស់ចំពោះវក្កលិភិក្ខុថា ៖

« អ្នកណាឃើញធម៌ អ្នកនោះឈ្មោះថាឃើញតថាគត » ។

សេចក្ដីពិត ពុទ្ធសាសនាពុំមានវិធីស្ដូតទេ វិធីបន់ស្រន់ អង្វរករក៏ពុំមានដែរ ព្រោះវិធីស្ដូត បន់ស្រន់ អង្វរករ ទាំងអស់នេះ ពុំមែនជានិយ្យានិកធម៌ «ធម៌ស្រោចស្រង់» ទេ ។ ព្រះសម្ពុទ្ធ ប្រោសសត្វដែលសូត្រស្ដូតបន់ស្រន់ឬអង្វរករព្រះអង្គពុំកើតទេ ។ ធម៌ព្រះអង្គជាធម៌ស្រោចស្រង់ខ្លួនឯង ( និយ្យានិកធម៌ ) ប្រែថា « សេចក្ដីបរិសុទ្ធិត្រូវធ្វើដោយខ្លួនឯង» ។ ព្រះសម្ពុទ្ធឃើញថា «សូត្រស្ដូតថ្វាយព្រះអង្គ ជាការឥតប្រយោជន៍» ហើយទ្រង់ពុំយល់ឃើញត្រឹមតែប៉ុណ្ណឹងទេ ទ្រង់ឃើញទៀតថា «ការសូត្រស្ដូតសុំក្ដីអនុគ្រោះនេះ ជាការបន្ទាបបន្ថោកខ្លួន ហើយធ្វើខ្លួនឲ្យមានគំនិតថោកទៀតផង» ។ ពុទ្ធសាសនិកជន ពុំគួរសូត្រស្ដូត ដើម្បីស្រោចស្រង់ខ្លួនទេ ត្រូវទុកចិត្តខ្លួនឯង ធ្វើខ្លួនឯង ដើម្បីសេរីភាពខ្លួនឯង ។

ពុទ្ធសាសនា ពុំមានអាទិទេព ពុំមានជំនឿចំពោះពហោមុភាពពិភព លោកដែលស្ថិតមាន ''ការចេះដឹងសព្វ ឬសព្វញ្ញុ,, (Omniscience) មានវត្តមានសព្វកន្លែង ឬសព្វព្រះហាន (Omnipresence) ពុំមានទិដ្ឋិ (Dogma) ដែលត្រូវប្រកាន់ជឿ, ពុំមានលទ្ធិ (Creed) ដែលត្រូវទទួលជឿ (Foi) ពុំមានព្រាហ្មណ៍ធ្វើជាអាជ្ញាកណ្តាល រវាងមនុស្សនិងអាទិទេព, ពុំមានពិធីពិសេស (Rite), ពុំមានពិធីសំស្ការ(១) ធ្វើឲ្យកើតបានជាពុទ្ធសាសនិកជន, ពុំមានបន្ទូរ (បទសូត្រស្តុតិ) ឬយញ្ញពិធី, ពុំមានការប្រព្រឹត្តិព្រហ្មចរិយតិកបធម៌ ឬយោគធម៌ ដើម្បីស្រោចស្រង់ខ្លួនទេ ។

ដូច្នេះ ពុទ្ធសាសនា អ្នកផងពុំគប្បីហៅថា Religion (លទ្ធិសាសនា) ពេញត្រង់មាត់សោះ ព្រោះពុទ្ធសាសនាពុំមែនជាប្រព័ន្ធ (Systeme) នៃជំនឿគោរពបូជាផល (Foi, និងការបូជា (Culte) ទេ ឬមិនជា ''អំណាចដែលជីកចាំមនុស្សឲ្យរួលស្គាល់អាទិទេព ឬអាទិទេពត្រូវមានអនុភាពលើសលប់ខ្ពស់ជាងមនុស្ស ហើយមនុស្សត្រូវតែគោរពបូជាស្រុកស្តុតិបារមីគុណសប្បុរសគុណវិញ,, ដូច្នេះក៏ទេដែរ ។

បើមិនហៅពុទ្ធសាសនាថា Religion ''លទ្ធិសាសនា,, ដោយមានអត្ថន័យថា ''ជាពុទ្ធវចនៈដែលស្ថិតជីវិត ចូលទៅដល់ក្នុងជីវិត តាមយថា-ភូតសម្បញ្ញាណ ពុំមែនគិតស្មើៗតែសំបកក្រៅៗទេ, ជាពុទ្ធវចនៈស្ថិតដំបូន្មាន ផ្តល់ឲ្យមនុស្សប្រព្រឹត្តិ ទេះដើរខ្លួនឯង ទៅតាមគន្លងដំបូន្មាន

១ - ពិធីប្រសិទ្ធិឲ្យបានជាព្រាហ្មណ៍ ។

ល្អិតសុខុមត្រឹមត្រូវវិសេស, ជាព្រះវចនៈស្ដីពីដំបូន្មាន បង្រៀនមនុស្សឲ្យ មានចិត្តមានះតស៊ូយកឈ្នះខ្លួនឯង ចេះរស់ក្នុងជីវិតដោយប្រយ័ត្ន ចេះតស៊ូ ចំពោះសេចក្ដីស្លាប់ មិនរួញរា មិនថយ មិនញញើត ដោយខន្តីធម៌ ជាព្រះវចនៈទុកជាអាគមសក្តិសិទ្ធិ ស្ដោះបណ្ដុះបណ្ដាលក្ដីប្រសើរ ក្ដីល្អ ក្ដីរីករាយឲ្យកើតដល់ខ្លួនឯង និងដល់ជនដទៃទៀត,, ។ បើព្រះសាសនា ជាលទ្ធិសាសនា មានអត្ថន័យដូចពោលមកខាងលើនេះមែន ទុះលទ្ធិ. សាសនានេះឯង ប្រាកដជាប្រសើរលើស លើលទ្ធិសាសនាទាំងឡាយ (A religion of religions) ។

×

× ×

# ព្រះធម៌ដែលព្រះសម្ពុទ្ធសម្តែងប្រោសសត្វ
# ជាទស្សនវិជ្ជាឬអ្វី ?

ព្រះធម៌ ឬហៅថា «ធម្ម» ដែលព្រះសម្ពុទ្ធសម្តែងហើយនេះឬ ដែលអ្នកបស្ចិមហៅថា «ទស្សនវិជ្ជា» ( Philosophie ) ? ក្នុងអតីតកាល មានព្រះសម្ពុទ្ធច្រើនព្រះអង្គ ដែលទ្រង់បានកន្លងលើសទៅយូរអង្វែងណាស់ហើយ តែព្រះធម៌ប៉ុណ្ណោះសល់ដែលទ្រង់បានសម្តែងទុកហើយ ដើម្បីប្រោសសត្វលោកនេះ មិនប្រែទៅ បរិសុទ្ធតាមរូបដើមដដែល ហេតុនេះហើយបានជាព្រះធម៌នេះហៅថា **បកតិធម៌** «ធម៌ប្រក្រតី» ។

ព្រះធម៌នេះ កាលព្រះអង្គគង់ធរមាននៅឡើយ មិនមានចារឹកជាអក្សរទេ ។ ក្រោយពុទ្ធបរិនិព្វាន ព្រះអរិយសាវកទាំងឡាយច្រើនអង្គបានធ្វើសង្គាយនា (១) ( ច្រៀងផ្ទាត់ ) ពុទ្ធវចនៈហើយចេះចាំព្រះពុទ្ធវចនៈទាំងអស់ចាំរត់មាត់ស្ទាត់ ( មុខបាឋ ) បានរក្សាព្រះធម៌ជាពុទ្ធវចនៈតៗគ្នា ពីជំនាន់មួយទៅជំនាន់មួយទៀត រហូតដល់បច្ចុប្បន្នកាលនេះ ។ ពុទ្ធសាសនាកន្លងទៅប្រមាណជា ៥០០ ឆ្នាំ ព្រះសង្ឃសាវកចារឹកពុទ្ធវចនៈជាលាយលក្ខណ៍អក្សរនៅកោះលង្កា ។ ព្រះសម្ពុទ្ធសម្តែងទុកជា ធម៌ព្រះអង្គនេះហៅថា ធម្មវិន័យ គឺធម៌ ១ វិន័យ ១ តមកលោកចែកធម៌ជាពីរប្រការ គឺធម៌ដែលមានអាចក់កះហៅថា «ព្រះសូត្រ» ធម៌ដែលមានអាថ៌ជ្រាលជ្រៅហៅថា «ព្រះអភិធម្ម» កើតបានទៅជា ៣ ផ្នែក គឺ ព្រះវិន័យបិដក

---

១– មើលសៀវភៅ «ព្រះត្រៃបិដកជាភាសាខ្មែរ» នៅពុទ្ធសាសនបណ្ឌិត្យ

(មាន ១៣ សៀវភៅ) សុត្តន្តបិដក (មាន ៦៣ សៀវភៅ) អភិធម្ម-បិដក (មាន ៣៤ សៀវភៅ) រួមហៅថា តិបិដក ឬ ត្រៃបិដក ឬគឺ ល្អីបី ( Trible corbeille ) ។

១– វិន័យបិដក «ហៅវិន័យ», ជាច្បាប់ក្រិត្យក្រម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្ត អនុញ្ញាត ទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់សង្ឃគឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ វិន័យនេះ ចែកជាពីរប្រការទៀតគឺ

ក) អាគារិវិន័យ «វិន័យអ្នកមានផ្ទះ» វិន័យសម្រាប់គ្រហស្ថ ឧបាសក ឧបាសិកាប្រតិបត្តិ ។

ខ) អនាគារិវិន័យ «វិន័យអ្នកមិនមានផ្ទះ» បានដល់ពួកបួសគឺភិក្ខុ ភិក្ខុនីប្រតិបត្តិ ។

២– សុត្តន្តបិដក ឬ ព្រះសូត្រ បានដល់ធម៌ដែលព្រះសម្ពុទ្ធសម្ដែងក្នុងសម័យផ្សេងៗ កាលដែលទ្រង់គង់នៅមានព្រះជន្មនៅឡើយ ។ ក្នុងព្រះសូត្រនេះ ព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះកស្សប ឬ ព្រះសាវកដទៃទៀត សម្ដែងក៏មានដែរ ។

៣– អភិធម្មបិដក ឬ ព្រះអភិធម្ម សំដៅបរមត្ថធម៌ដ៏ជ្រាលជ្រៅ បានដល់ធម៌ស្រួចម៉ត់ មានអាថ៌ជ្រាលជ្រៅរបស់ព្រះសម្ពុទ្ធ ជាការខុសប្លែកពីសុត្តន្តបិដក ដែលមានសេចក្ដីពាក់ៗគឺ សុត្តន្តបិដក ជាវោហារទេសនា ( Conventional teaching ), ឯអភិធម្មបិដក ជាបរមត្ថទេសនា (Ultimate teaching) ។ ក្នុងគម្ពីរអភិធម្ម ព្រះសម្ពុទ្ធសម្ដែងពីធម៌ល្អិតសុខុមគឺ

ស្ដីពីចិត្ត ( Consciousness ), ចេតសិក ( Mental concomitants ), រូប ( Matter ) និងនិព្វាន ។ នៅក្នុងអភិធម្មនេះហើយដែលព្រះសម្ពុទ្ធសំដែងថា សត្វទាំងឡាយគ្រាន់តែជាបុគ្គល "បុគ្គលបញ្ញត្តិ = គ្រាន់តែជាបញ្ញត្តិបុគ្គល", មិនថាជាសត្វក៏ពុំមែន មិនថាមានជីវិតក៏ពុំមែន ជាធម៌សុទ្ធ= និស្សត្តា និជ្ជីវា សុញ្ញា ដោយការញែកយ៉ាងល្អិតបំផុត គ្រាន់តែញែកទៅទៀតពុំបាន ព្រមទាំងបែកធម៌ទាំងនេះដោយបរិយាយជាអនេកប្រការយ៉ាងម៉ត់ចត់បំផុតទៀត ។

មួយទៀត អភិធម្មនេះ ស្ដីពីសច្ចធម៌ (Truth) និងភូតធម៌ ( Fact ) មិនស្ដីពីប្រឌិត ឬទស្សនវិជ្ជា ដែលគេទុកដូចជាសច្ចធម៌មានក្ដីជ្រាលជ្រៅបានតែពេលនេះ ហើយដល់ថ្ងៃស្អែក គេបដិសេធពេលនោះវិញ ដោយឃើញមិនពិតដូច្នេះទេ ។ ព្រះសម្ពុទ្ធសំដែងធម៌ប្រដៅសត្វទាំងឡាយ ជាធម៌ប្រាកដ ពុំមែនជាធម៌នាំឲ្យគេភ័យខ្លាចនោះទេ ពុំមែនជាប្រឌិតទស្សនៈវិជ្ជាដែលបង្ខំគេឲ្យទទួលធម៌នោះទេ ឬមិនថាជាធម៌ដែលទ្រង់បានបង្កើតជាបែបវិទ្យាសាស្ត្រសម្ភារនិយមដូច្នោះក៏ទេដែរ ។ ទ្រង់តែងសំដែងធម៌ប្រោសប្រៀនប្រដៅដោយពន្យល់ថា "ធម៌នេះជាមាគ៌ាគួរប្រតិបត្តិ ធម៌នេះពុំគួរប្រតិបត្តិ", ដែលសុទ្ធតែជាធម៌នាំសត្វឲ្យរួចចាកទុក្ខ ហើយទីបំផុតទ្រង់ចង្អុលផ្លូវប្រតិបត្តិទៅកាន់មោក្ខធម៌ ជាផ្លូវតែមួយគត់ (= ឯកាយនោ មគ្គោ ) ។ បើពិនិត្យមើលឲ្យសព្វគ្រប់ទៅ ធម៌ព្រះអង្គជាធម៌ដូចជាបើកបញ្ញាញាណដល់អ្នកវិទ្យាសាស្ត្រ ទស្សនវិទូច្រើននាក់ ឲ្យដើរតាមក្រោយព្រះតម្រិះ

ព្រះអង្គទៀតផង ។ សេចក្ដីនេះ លោក ស្វប៉េនហៅ ( Schopenhauer )
សរសេរថា "សេចក្ដីទុក្ខជាសច្ចធម៌ ហើយគំនិតនេះបានជាមាគ៌ា
ដើរនៃទស្សនវិទូបស្ចិមសព្វថ្ងៃនេះទៀតផង,, ។ លោក ស្ពីនោ
ស៊ា ( Spinoza ) ក៏ពោលបដិសេធគោលទ្រឹស្ដីទាំងឡាយដទៃដែរ ដោយ
លោកពោលថា "សភាវធម៌ដែលលោកថា «ថេរនៅនិត្យនេះ» មិន
មានប្រាកដការនិយមទេ,, លោកបញ្ជាក់ទៀតថា "សភាវធម៌ទាំង
អស់ ដែលថា «ថេរនៅនិត្យ» សុទ្ធតែមានការប្រែប្រួលធម្ម-
តា,, ។ ចំពោះមតិលោកនេះ លោកយល់ថា « ទុក្ខនេះ មនុស្សអាច
យកឈ្នះបាន ដោយរកឃើញធម៌គឺវិជ្ជា ដែលពុំមែនជាធម៌កើត
មានមួយស្របក់ និងពុំមែនជាធម៌កើតមានមួយភ្លែត តែជាធម៌
ឥតកែប្រែបាន ថេរនៅនិត្យ ថេរចិរកាល » ។ លោក ប៊េរក្លេយ
( Berkley ) យល់ច្បាស់ថា "អ្វីដែលជាបរមាណូវិញកពុំបាននេះ គេ
ប្រតិតខុកតែខាងបរមត្ថវិជ្ជាទេ គ្រាន់តែជាល្បែងលេង,, ។ ហើយលោក
ហ្យូម ( Hume ) ក្រោយដែលលោកកែវញែកពីរឿងចិត្ត ( Mind ) មក
កាលយូរ លោកពោលសរុបសេចក្ដីថា "វិញ្ញាណ គឺធម្មជាតិដែលហូរ
ទៅនៃចិត្ត,, ។ ឯលោក បែរសុង ( Bergson ) ពន្យល់ប្រាប់ថា "នេះ
គឺច្បាប់នៃការប្រែប្រួល,, ។ ចំណែកលោកសាស្ត្រាចារ្យ ជែម
( James ) នាំយើងឲ្យយល់ថា "នេះគឺក្រសែចិត្ត,, ។

ធម៌ដែលអ្នកប្រាជ្ញទាំងឡាយដួញចិត្តត្រិះរិះគិតទាំងអស់នេះ ព្រះ

សម្ពុទ្ធបានត្រាស់ទេសនាប្រោសសត្វប្រមាណជា ២ ៥៥៧ រួចមកហើយ ទៅតាមជនមហាជនវិតក្កានៃប្រទេសណា គឺទ្រង់ទេសនាប្រាប់ថា **នេះគឺអនិច្ចតាធម៌** "ធម៌ប្រែប្រួលកើតមានតែមួយស្របក់ ( ឧប្បាទធម៌ = **Transieney** ) **នេះគឺទុក្ខ** "ធម៌ដែលត្រាំទ្របានដោយលំបាកណាស់ ( **Sarrow** ) ,, **នេះគឺអនត្តា** "ធម៌ដែលមិនមែនជារបស់ខ្លួនឯង **(No soul)**,, ហៅថាព្រះត្រៃលក្ខណ៍ ឬសាមញ្ញលក្ខណៈ "លក្ខណៈធម៌ដែលជាច្បាប់ទៀងទាត់បំប្រការ,, ឬ "លក្ខណៈធម្មតាទាំងឡាយ ដែលតែងកើតមានឡើងជាប្រក្រតី,, ។ មួយទៀត អ្នកសិក្សាពុទ្ធវចនៈ គប្បីយល់ថា ព្រះសម្ពុទ្ធទ្រង់ទេសនាធម៌ប្រោសសត្វទាំងឡាយ ទ្រង់ពុំបានទេសនាធម៌ទាំងអស់ ដែលទ្រង់ត្រាស់ដឹងនោះទេ ទ្រង់ទេសនាចំពោះតែធម៌ណាដែលដឹកនាំសត្វទៅកាន់វិមុត្តទុក្ខ គឺអមតមហានិព្វាន ។ សេចក្តីនេះមានប្រាកដនៅក្នុងគម្ពីរសំយុត្តនិកាយ មហាវគ្គថា :

ថ្ងៃមួយ ព្រះសម្ពុទ្ធ ទ្រង់ប្រថាប់នៅក្នុងសីសបាវន៍ ជិតក្រុងកោសម្ពី ពេលនោះទ្រង់ឈោងព្រះហស្តទៅចាប់ស្លឹកឈើមួយក្តាប់មក ហើយទ្រង់លើកឡើង រួចត្រាស់ទៅកាន់ភិក្ខុសង្ឃថា :

**" អ្នកទាំងឡាយ ! ស្លឹកឈើដែលនៅក្នុងក្តាប់ដៃតថាគតនេះ និងស្លឹកឈើដែលនៅលើដើមឈើទាំងឡាយ ណាច្រើនជាងណា ? ,,**

*ភិក្ខុសង្ឃក្រាបទូលសួរព្រះពុទ្ធដីកាវិញថា*

"សូមទ្រង់ព្រះមេត្តាប្រោស ! ស្លឹកឈើនៅក្នុងក្តាប់ព្រះហស្ត តិចណាស់ ស្លឹកដែលនៅលើដើមឈើ ច្រើនក្រៃលែងច្រើន ច្រើនលើសនឹងគណនាព្រារាប់បាន „។

*ពេលនោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់តទៅទៀតថា :*

" អើភិក្ខុទាំងឡាយ ! ធម៌ដែលតថាគតត្រាស់ដឹងនោះច្រើនណាស់ ដូចស្លឹកឈើដែលនៅលើដើមឈើ ហើយធម៌ដែលតថាគតយកមកសម្តែងប្រាប់អស់អ្នកទាំងឡាយនេះតិចណាស់ ដូចជាស្លឹកឈើដែលនៅក្នុងក្តាប់ដៃតថាគតនេះឯង។ តែធម៌ដែលតថាគតមិនបានយកមកសម្តែងប្រាប់អ្នកទាំងឡាយ ជាធម៌មិនមានប្រយោជន៍នឹងដឹកនាំអ្នកទាំងឡាយទៅកាន់ទីបំផុតទុក្ខទេ„ ។

*ធម៌ដែលព្រះសម្ពុទ្ធយកមកសម្តែងប្រោសសត្វទាំងឡាយ សុទ្ធតែជាធម៌មានប្រយោជន៍នឹងនាំសត្វទាំងឡាយទៅកាន់ទីបំផុតទុក្ខពិតប្រាកដ ជាធម៌គួរល្មមដល់មនុស្សទាំងឡាយចាប់យកសេចក្តីហើយយល់បាន ជាធម៌ប្រកបដោយហេតុផលបរិបូណ៌ ហើយច្បាស់លាស់ប្រាកដការនិយម មានលក្ខណៈជាវិទ្យាសាស្ត្រ បើបុគ្គលណាមួយបានសិក្សាធម៌ទាំងនេះហើយ នឹងបានយល់ច្បាស់ ឃើញច្បាស់ មើលអ្វី មើលឃើញពិតដោយពិត ដោយយថាភូតទស្សនញាណ ជាធម៌ដែលអ្នកប្រាជ្ញបច្ចុប្បន្នកាលនេះ ទទួលស្គាល់ថាត្រឹមត្រូវ ហើយគេកោតស្ញើចក្រៃលែង ។*

សេចក្តីពិត ពុទ្ធសាសនានិងវិទ្យាសាស្ត្រមានលក្ខណៈស្របគ្នា ដើរទៅតាមផ្លូវជាមួយគ្នា ៗ រឿងនេះ មិនមានទោសជាប់ឈ្មោះគួរឲ្យមានមោះមន្ទិលៈឡើយ គ្រាន់តែមួយជាផ្លូវធម៌ស្តីពីសីលធម៌និងបរមត្ថសច្ច ( Moral and spiritual truth) មួយទៀត ជាផ្លូវលោក ស្តីពីសម្មតិសច្ច ( Material truth ) ពោលគឺពុទ្ធសាសនាយកខ្លួនប្រើជាឧបករណ៍ សម្រាប់ធ្វើនិទស្សន៍រកសច្ចធម៌ ហើយប្រើតែខាងផ្នែកសីលធម៌ ឬផ្លូវចិត្ត ហៅនិរាមិសនិយម ឬមិនហៅថា អរូបនិយមក៏បាន ឯវិទ្យាសាស្ត្រយកវត្ថុដដែលទៅត្រឹមខ្លួនជាឧបករណ៍មកធ្វើជាជំនួយជួយធ្វើនិទស្សន៍រកសច្ចធម៌ ហើយយកទៅប្រើខាងផ្នែកសម្ភារនិយម ឬអាមិសនិយម ឬក៏មិនហៅថា រូបនិយមក៏បាន ៗ បើនិយាយជាសេចក្តីមួយបែបទៀត ពុទ្ធសាសនារកសេចក្តីសុខនៅនាលោកនេះផង រកបរមសុខនៅឯបរលោកផង ដែលហៅថា និរាមិសសុខ ៗ ឯវិទ្យាសាស្ត្ររកសេចក្តីសុខ នៅតែក្នុងលោកនេះតែម្យ៉ាង ដែលហៅថា អាមិសសុខ ៗ ដូច្នេះ គោលការពុទ្ធសាសនានិងវិទ្យាសាស្ត្រទាំងពីរនេះផ្សេងគ្នា ៗ

មួយទៀត ធម៌ដែលអង្គព្រះសម្ពុទ្ធសម្តែងប្រោសសត្វ ដោយពិតពុំមែនជាគ្រឿងតាំងទុកសម្រាប់លំអនៅក្នុងបណ្ណាល័យទេ ឬមិនជាជាធម៌ ឬវិជ្ជាសម្រាប់សិក្សាបែបជាប្រវត្តិសាស្ត្រ បែបជាអក្សរសាស្ត្រក៏ពុំមែនទេ ឬក៏មិនជារឿងទុកសម្រាប់បង្ហួតអ្នកប្រាជ្ញ ឬក្នុងអ្នកបញ្ញវន្តទាំងឡាយក៏ទេដែរ ៗ ធម៌ព្រះអង្គជាធម៌សម្រាប់សិក្សាឲ្យចេះដឹងហៅថា **បរិយត្តិធម៌** "រៀនសូត្រឲ្យចេះដឹង" រៀនសូត្រចេះដឹងហើយត្រូវប្រតិបត្តិតាមហៅ

៣ **បដិបត្តិធម៌** «ធ្វើតាមធម៌ដែលបានរៀនសូត្រចេះដឹងហើយ» បើបានប្រតិបត្តិត្រឹមត្រូវតាមគន្លងធម៌នេះហើយ មិនបាន **ផលគឺការត្រាស់ដឹង** «សម្មាសម្ពុទ្ធិញាណ» ហើយបានសម្រេច **លោក្យធម៌** «ការរួចចាកទុក្ខទាំងពួង» ហៅថា **បដិវេធធម៌** «ការត្រាស់ដឹងធម៌» បានសេចក្ដីថាធម៌ព្រះអង្គនេះសម្រាប់រៀនឲ្យចេះ ចេះហើយធ្វើតាម ធ្វើតាមហើយ បានផលផ្លែផ្កា គឺសេចក្ដីសុខនៅក្នុងបច្ចុប្បន្នជាតិនេះផង និងជាដំណើរដើរទៅកាន់បរមសុខនៅក្នុងលោកុត្តរធម៌ផង ។ អ្នកប្រតិបត្តិតាមធម៌ព្រះអង្គ ពិតជាបានសេចក្ដីសុខនៅលោកនេះផង ហើយពិតជាបានរលុះទីបំផុតទុក្ខ ដែលយើងធុញទ្រាន់ជិនណាយនេះឥតសង្ស័យឡើយផង ព្រោះជាទីបំផុតទុក្ខនេះឯងហើយ ជាគោលដៅនៃសាសនារបស់សត្វទាំងអស់ ។

ដូច្នេះ ធម៌ព្រះអង្គ ពុំមែនគ្រាន់តែល្អមើលទេ គឺទុកជាសំពៅកេត្រាសម្រាប់ជិះឆ្លង ហើយចម្លងសត្វឲ្យរួចផុតអន្លង់ទុក្ខ គឺមហាសាគរ ដែលហៅថា «វដ្ដសង្សារ» (ការអន្ទោលស្លាប់កើត) ។ តាមទំនងនេះ ពុទ្ធសាសនាមិនទុកជាយ៉ាងចំហជាទស្សនវិជ្ជា (Philosophie) ពុំបានឡើយ ។

# ពុទ្ធសាសនាជាប្រព័ន្ធសីលធម៌ឬអ្វី ?

សេចក្ដីពិត ពុំគួរមានសេចក្ដីសង្ស័យចំពោះពុទ្ធសាសនានេះទេ ។ ពុទ្ធសាសនាពិតជាច្បាប់សីលធម៌ ( Système éthique ) ដ៏ប្រសើរបំផុត ជាច្បាប់សមប្រតិបត្តិគ្រប់សម័យដោយប្រពៃ ប្រសើរលើសសីលធម៌ធម្មតាសកលលោកថែមទៀត ។ សីលធម៌ដែលព្រះសម្ពុទ្ធសម្ដែងទុកនោះសុទ្ធជាសីលធម៌ខ្ពស់ផុត ជាលំអានដើមនៃកុសលធម៌ទាំងពួង ជាមាគ៌ាដ៏ត្រឹមដឹកនាំសត្វទៅកាន់ទីបំផុតទុក្ខដែលជាគោលដៅទីបំផុត ។ សីលធម៌ធម្មតាសកលលោក ជាច្បាប់សារវន្តពិតមែន តែពុំមែនជាច្បាប់ពេញលក្ខណៈបរិបូណ៌ ក្នុងការដឹកនាំសត្វលោកឲ្យលុះសេរីភាព (liberté) បរិបូណ៌គោលគឺមោក្ខធម៌នោះឡើយ ។ សីលធម៌ធម្មតាសកលលោក បើនឹងមានប្រសិទ្ធភាពពេញលេញ លុះត្រាតែប្រកបដោយបញ្ញាចំណេះវិជ្ជាផ្សេងទៀតផង ទើបសមគួរនឹងបានចូលរាប់ជាសីលធម៌ប្រសើរពិតមែន ។

ពុទ្ធសាសនាសំដៅ **កម្ម** «អំពើ» ( Action ) គឺអំពើល្អ អាក្រក់ អព្យាក្រឹត ( កុសលកម្ម អកុសលកម្ម អព្យាកតកម្ម ) ។ កម្មជាច្បាប់ធម្មជាតិ ពុំមែនជាច្បាប់តុលាការទេ ។ ច្បាប់តុលាការ ប្រកបដោយភ័យច្រើនណាស់ ។ សូមប្រាប់ថា កម្មដែលសំដៅក្នុងពុទ្ធសាសនា គឺកម្មមានចេតនា ។ ចេតនា គឺបល ចេតនាគឺកម្ម ។ កម្មនេះពិតជាឲ្យផលវិបាកខ្លួនឯងពិត ព្រោះកម្មមានចេតនា ។ ឯកម្មមិនមានចេតនាពុំសំដៅក្នុងពុទ្ធសាសនាទេ ។ កម្មទាំងអស់ មានគុណានុភាពក្នុងខ្លួនឯង ហើយ

ធ្វើការជាកិច្ចការខ្លួនឯង ចូរមើលចលនាមហាក្សត្របច្ចុប្បន្ន ធ្វើការក្នុងខ្លួនជានិច្ច ៗ ដូច្នេះ កម្ម គឺអ្នកនិម្មិត ឬ ស្ថាបនិក ( Architecte ) សាងអ្វី ៗ ទាំងអស់ក្នុងលោក ។ បើ អាទិទេព ព្រហ្មនី ឬ តៅ មានអត្ថន័យជា «កម្ម» វិញ នុះមានសេចក្តីប្រសើរណាស់ ។ គួរសាធុជនគោលជាពុទ្ធសាសនានេះជា លទ្ធិកម្មនិយម ( លទ្ធិសក្តិកម្ម ) បានយ៉ាងបរិបូណ៌ ។

បណ្តាកម្ម៣ ប្រការខាងដើម អំពើល្អ (កុសលកម្ម) នាំមកការវឌ្ឍបំផុត ក្នុងការកសាងខ្លួនបុគ្គលម្នាក់ ៗ ឲ្យបានជាបុគ្គលប្រសើរ ហើយឲ្យរួចចាកទុក្ខគ្រប់ប្រការ ដោយការបំពេញព្រហ្មចរិយធម៌បរិបូណ៌ ដូចមានសេចក្តីក្នុងអង្គុត្តរនិកាយ ដែលអង្គព្រះសម្ពុទ្ធត្រាស់ថា :

«ព្រះធម៌ (កុសលធម៌) ដែលបុគ្គលម្នាក់ៗបានចម្រើនហើយ បានធ្វើឱ្យមានច្រើនច្រើនហើយ ច្រើនទាល់តែលើសលប់អាចកន្លងបង់នូវអធម៌ (អកុសលធម៌) ទាំងអស់បាន ពិតប្រាកដ» ។

កម្ម (អំពើ) នៃព្រះអរហន្តជាកិរិយាស្រេច ពុំមែនជាកុសល ឬអកុសលទេ ព្រោះសន្តានចិត្តរបស់លោកបានកន្លងផុតបង់ទាំងពីរប្រការនេះអស់ហើយ ។ តែសេចក្តីនេះ ពុំមែនមានន័យថា «ព្រះអរហន្តអស់ការងារទេ» គោលគឺមិនមានសេចក្តីថា «ព្រះអរហន្តនៅស្ងៀមព្រងើយកន្តើយ» ( passive ) (១) ទៀយ ហើយពិត ព្រះអរហន្តជាអ្នកសកម្ម ( Active ) ប្រសើរលើសជនសាមញ្ញទៅទៀត តែសកម្មភាពរបស់លោក ជាសកម្ម-

១— He is passive ។

ភាពឥតវិបាក ដែលហៅថា. «កិរិយា (១)» ហើយជាសកម្មភាពដឹកនាំសត្វឲ្យដើរទៅតាមមាគ៌ាដ៏ប្រសើរ ដែលលោកបានត្រាស់ដឹងពិតតាមពិត ឆ្ពោះទៅកាន់សិវិដ្ឋានក្សេមក្សាន្តនិរទុក្ខនិរភ័យ ។ សកម្មភាពរបស់លោក តាមធម្មតា ជាអំពើកុសល ជាអំពើមានអានុភាពខ្លាំង ដឹកនាំសត្វ-លោកឲ្យបានសម្រេចប្រយោជន៍. ឧបមាដូចមាស មាសដែលជាងមាសដេញឲ្យអស់មន្ទិលហើយ ជាវត្ថុធាតុបរិសុទ្ធមិនបាច់ដេញទៅទៀតយ៉ាងណា ព្រះអរហន្តជាវត្ថុធាតុបរិសុទ្ធមិនមានករណីយកិច្ចដែលជាកម្មវិបាកតទៅទៀតទេ យ៉ាងនោះដែរ ។ ព្រះអរហន្ត យល់ច្បាស់ធម៌ ចាក់ធ្លុះធម៌ពិតតាមពិតដោយពិត ត្រាស់ដឹងធម៌ ជាធម៌មានភាពបំផ្លាញបង់នូវសង្សារចក្រពោលគឺបដិច្ចសមុប្បាទធម៌ «ធម៌ជាច្បាប់ហេតុផល» ។

សេចក្តីដូចបានពោលមកនេះ គួរលើកមកបញ្ជាក់ម្តងទៀតថា «លក្ខ-ណៈអ្វីជាអាទិទេព ដែលថាមានអានុភាពលើអ្វីទាំងអស់ ឬអ្វីផ្សេងទៀតដែលជាភាពកំណាន់អាទិទេពមានឫទ្ធានុភាពនោះ ពុំមានចំណែកណាមួយចាល់តែសោះនៅក្នុងលក្ខណៈពុទ្ធសាសនា» ក្នុងពុទ្ធសាសនាពុំមានអ្នកណាមួយជាអ្នកចាំប្រទានរង្វាន់ ឬជាអ្នកចាំដាក់បណ្តាសាឲ្យមានបាបនោះទេ ។ សុខក្តី ទុក្ខក្តី សុទ្ធតែជាផលដែលកើតចេញមកពីកម្ម «អំពើ» របស់ខ្លួនគ្រប់គ្នាទាំងអស់ ។ គំនិតដែលគិតថា ទេវតាពេញព្រះទ័យហើយប្រោសប្រទានរង្វាន់ក្តី ឬទេវតាមិនសព្វព្រះទ័យហើយក្រេវក្រោធ

---

១ កិរិយាដែលធ្វើ មិនឲ្យផលជាល្អជាអាក្រក់ ។

ដាក់បណ្ដាសាឲ្យមានបាបក្ដី ពុំមាននៅក្នុងសន្ដានចិត្តពុទ្ធសាសនិកជនទេ សូម្បីតែក្ដីសង្ឃឹមថា ទេវតានឹងប្រោសប្រណីប្រទានរង្វាន់ក្ដី ឬក្ដីបារម្ភថា ទេវតានឹងក្រោធដាក់បណ្ដាសាក្ដី ក៏ពុំមានដែរ ។ ពុទ្ធសាសនិកជន ជឿខ្លួន ចំពោះវិបាករបស់ខ្លួន ក្នុងអនាគតកាលជានិច្ច:

– មានសតិសម្បជញ្ញៈ តាំងចិត្តវៀរអំពើអាក្រក់ដោយកាយ វាចា ចិត្ត ព្រោះយល់ច្បាស់ថា អំពើអាក្រក់ឲ្យផលអាក្រក់ នាំឲ្យវេទទុក្ខវេទនា នៅនាលោកនេះនិងបរលោក ហើយជាហេតុនាំពន្យឺតដំណើរមិនឲ្យបាន សម្រេចនិព្វានឆាប់;

– តាំងចិត្តបំពេញកុសលធម៌ ព្រោះយល់ច្បាស់ថា អំពើល្អជួយ ស្រោចស្រង់ខ្លួនឲ្យបានក្ដីសុខនៅនាលោកនេះនិងបរលោក ហើយនាំខ្លួន ឲ្យវិលចូលទៅជិតសម្មាសម្ពោធិញ្ញាណ « ការត្រាស់ដឹង » ដែលជា គោលបំណងអវសានបំផុត ។

ដើម្បីយល់ច្បាស់នូវរបៀបធម៌ដ៏ត្រឹមត្រូវនេះ សូមអស់លោក អ្នក ទាំងឡាយ អញ្ជើញមើលពុទ្ធភាសិតនានា ដែលមាននៅក្នុងសូត្រ ទាំងឡាយ មានធម្មបទ សិង្គាលោវាទសូត្រ ព្យគ្ឃបជ្ជសូត្រ មង្គល សូត្រ ករណីយសូត្រ បរាភវសូត្រ វសលសូត្រ ធម្មិកសូត្រ ជាដើម ទៀតចុះ ។ ដូច្នេះ ពុទ្ធសាសនានេះ បើមើលតាមអត្ថន័យមួយបែប ពុំ មែនត្រឹមតែជាទស្សនវិជ្ជាប៉ុណ្ណោះទេ បើមើលតាមអត្ថន័យមួយបែបទៀត

ជាខ្សែទៅជាន់លើខ្សែទៅជាន់ទាំងឡាយទៅទៀត ។ ពុទ្ធសាសនានេះ បើមើលតាមអត្ថន័យមួយបែបពុំមែនត្រឹមតែជាលទ្ធិសាសនា (Religions) ទេ បើមើលតាមអត្ថន័យមួយបែបទៀត ជាលទ្ធិសាសនា លើលទ្ធិសាសនាទាំងឡាយ ។ ពុទ្ធសាសនានេះ បើនិយាយពីសីលធម៌ជាសីលធម៌ប្រសើរលើសលើវិធីសីលធម៌ទាំងឡាយ ។ សីលធម៌នេះទៀត ពិតជាខាងដើមនៃសេចក្តីល្អ (កុសលធម៌) ទាំងឡាយ ហើយសូមជ្រាបថា ពុំមែនជាទៅចុងបំផុតនៃពុទ្ធសាសនាទេ ។

ពាក្យថា «ពុទ្ធសាសនា» បើតាមអត្ថន័យជាភាសាបាលី ដែលជាសំណៅដើម លោកប្រើពាក្យថា «ធម្ម» ជាពាក្យដែលលោកលើកយកមកប្រើសម្រាប់ហៅ «ពុទ្ធសាសនា» ។ ពាក្យថា «ធម្ម» មិនមានអត្ថ-ន័យ ក្នុងភាសាដទៃណាមួយ ឲ្យមានសំនួនពេលហាប៉ុនគ្នាឡើយ ។ ឯពាក្យថា «ធម្ម» នេះបានប្រាកដការនិយម គោលគឺជាលក្ខណៈដែលស្តីពីសច្ចធម៌ជាធម៌ពិតដ៏ប្រសើរ ដឹកនាំសត្វទៅកាន់សេរីភាព ទៅកាន់ការរួចស្រឡះ=មោក្ខធម៌ (ការរួចស្រឡះដោយខ្លួនឯង) ។ ធម៌នេះ ទោះបើព្រះសម្ពុទ្ធកើតឡើងក្តី មិនកើតឡើងក្តី តែងតែជាធម៌ប្រាកដការនិយមជាប្រក្រតី ។ ព្រះសម្ពុទ្ធ គ្រាន់តែជាអ្នកបើកធម៌នេះ បង្ហាញឲ្យមើលឃើញប្រត្យក្សដូចជាបើកគម្របដែលគ្របលាក់ត្រូវមួយ ឲ្យមើលឃើញតែប៉ុណ្ណោះទេ ព្រោះថាធម៌នេះកប់បាត់នៅក្នុងអវិជ្ជាធម៌របស់មនុស្សទាំងឡាយ លុះព្រះអង្គបានត្រាស់ដឹងធម៌ហើយ ទើបទ្រង់ប្រកាសធម៌នេះឡើង ដល់មនុស្ស

ទេពតាព្រហ្មទាំងឡាយ ដោយករុណាធម៌របស់ព្រះអង្គ ។ បើប្រៀបធៀបជាសេចក្តីឲ្យឃើញពិត ធម៌នេះជាគេនៅតែដូចពេជ្រកប់នៅក្នុងគំនរអាចម៍ ព្រះពុទ្ធទ្រង់ជាអ្នកឃើញធម៌គឺពេជ្រនេះ ហើយគាស់កកាយយកមកបង្ហាញសត្វទាំងឡាយថា "នេះធម៌ នាំអ្នកទាំងឡាយទៅកាន់ឥស្សរភាព (មោក្ខធម៌) ផុតអន្ទង់ទុក្ខគ្រប់ប្រការ" ។

ដូច្នេះ សាធុជនទាំងឡាយ ជាអ្នកស្រឡាញ់ខ្លួន គួរប្រតិបត្តិតាមពុទ្ធសាសនានេះចុះ អស់លោកអ្នក នឹងបានក្តីសុខសម តាមប្រាថ្នាពុំខានឡើយ ។

×

× ×